**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ......២០៣.................ក.ប /ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីថ្លែងការអំពីបំណងប្រាថ្នាចង់ឱ្យប្រាកដថា លក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសម្លៀកបំពាក់នៅកម្ពុជា ស្របតាមបទដ្ឋានការងារសំខាន់ៗដែលទទួលស្គាល់ជាអន្តរជាតិ និងច្បាប់ស្តីពីការងារកម្ពុជា ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០
- យោងអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣
- យោងប្រកាសលេខ ២៤៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួង

# សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖



ឃ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**១-សមាជិកពេញសិទ្ធិ**

ក-តំណាងរាជរដ្ឋាភិបាល

១- ឯកឧត្តម **ម៉ម វណ្ណៈ** រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២- ឯកឧត្តម **សេង សក្ដា** អគ្គនាយកការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣- ឯកឧត្តម **សុខ សុភ័ក្រ** អគ្គនាយកសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ខ-តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

១- លោកស្រី **វ៉ាន់ ប៉ោហ្វីន** សមាជិកប្រតិបត្តិ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

២- លោក **រ៉ម៉ុន តាំ** សមាជិកប្រតិបត្តិ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

៣- លោក **ខេន លូ** អគ្គលេខាធិការ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។

គ-តំណាងចលនាសហជីពកម្ពុជា

១- លោក **អាត់ ធន់** ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

២- លោកស្រី **ទេព គឹមវណ្ណារី** ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា

៣- លោក **វ័ត្ត មីនា** ប្រធានសហព័ន្ធសហជីពជាតិ នៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា។

**២-សមាជិកបម្រុង**

ក-តំណាងរាជរដ្ឋាភិបាល

១- លោក **ម៉ក់ ឧសភា** អគ្គនាយករងសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម

២- លោក **អ៊ុក ចាន់ធូ** ប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣- លោក **ឡេង តុង** ប្រធាននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ខ-តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

១- លោក **គាំង ម៉ូនីកា** អគ្គលេខាធិការរង នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

២- លោក **សោម ចំណាន** ប្រធានផ្នែកច្បាប់និងការងារ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

៣- លោក **ជាតិ ខេមរា** មន្ត្រីជាន់ខ្ពស់ផ្នែកការងារ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។

គ-តំណាងចលនាសហជីពកម្ពុជា

១- លោក **នួន ចន្ថា** អគ្គលេខាធិការសភាសម្ព័ន្ធសហជីពជាតិកម្ពុជា

២- លោក **យឹង ឈុន** ប្រធានសហព័ន្ធសហជីពជាតិកម្ពុជា

៣- លោកស្រី **យ៉ាង សុភ័ណ្ឌ** ប្រធានសហភាពសហជីពជាតិកម្ពុជា។

**ប្រការ២.-**

សមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យរាជរដ្ឋាភិបាល និងតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជាមានអាណត្តិពីរឆ្នាំ។ ដោយឡែក សមាជិកគណៈកម្មការប្រឹក្សាគម្រោងដែលតំណាងឱ្យចលនាសហជីពកម្ពុជាមានអាណត្តិប្រាំមួយខែ។

**ប្រការ៣**.-

គណៈកម្មការប្រឹក្សាគម្រោងមានសហប្រធានពីររូប គឺមួយរូបជាសហប្រធានអចិន្ត្រៃយ៍ និងមួយរូបទៀតជាសហប្រធានប្តូរវេន។ សហប្រធានអចិន្ត្រៃយ៍ ត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោងដែលតំណាងឱ្យរាជរដ្ឋាភិបាល។ សហប្រធានប្តូរវេន ត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជាសម្រាប់រយៈពេលប្រាំមួយខែដំបូង និងត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យចលនាសហជីពកម្ពុជា សម្រាប់រយៈពេលប្រាំមួយខែបន្ទាប់។ ការជ្រើសរើសសហប្រធានប្តូរវេន ត្រូវអនុវត្តតាមនីតិវិធីនេះសម្រាប់រយៈពេលប្រាំមួយខែបន្តបន្ទាប់ទៀត។

**ប្រការ៤**.-

ឯកឧត្តម **ម៉ម វណ្ណៈ** ត្រូវបានតែងតាំងជាសហប្រធានអចិន្ត្រៃយ៍ហើយលោកស្រី **វ៉ាន់ ប៉ោហ្វីន** តំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ត្រូវបានតែងតាំងជាសហប្រធានប្តូរវេនក្នុងរយៈពេលប្រាំមួយខែដំបូង។

**ប្រការ៥**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួង និងឯកឧត្តម លោក លោកស្រី ដូចមានក្នុងប្រការ ១ និងប្រការ ៤ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ក្រសួងពាណិជ្ជកម្ម

-សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

-ប្រធានទីប្រឹក្សាបច្ចេកទេសគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

-ប្រធានគម្រោងអប់រំដល់ចលនាសហជីពកម្មករកម្ពុជា

-ក្រុមការងារអន្តរជាតិវិស័យការងារ

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ